# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ....៧៣....អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាកលវិទ្យាល័យស្វាយរៀង

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តស្វាយរៀង

## ស ម្រេ ច

**មាត្រា ១..**

បង្កើតសាកលវិទ្យាល័យមួយ ស្ថិតនៅផ្លូវជាតិលេខ ១ ភូមិចំបក់ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដែលមានឈ្មោះថា សាកលវិទ្យាល័យស្វាយរៀង " Svay Rieng University " ហៅកាត់ជាភាសាខ្មែរ "ស.ស.រ" និង ហៅកាត់ជាភាសាអង់គ្លេស "S.R.U" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២..**

សាកលវិទ្យាល័យស្វាយរៀង មានតួនាទី ជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស និង លើកស្ទួយអត្តសញ្ញាណជាតិ ។

**មាត្រា ៣..**

ចំពោះមុខសាកលវិទ្យាល័យស្វាយរៀង ធ្វើការបណ្តុះបណ្តាលកំរិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ ។ កម្មវិធី-សិក្សា ត្រូវមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤..**

សាកលវិទ្យាល័យស្វាយរៀងមាន ៥ មហាវិទ្យាល័យ :

១- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស

២- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៣- មហាវិទ្យាល័យសង្គមសាស្ត្រ

៤- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម

៥- មហាវិទ្យាល័យកសិកម្ម

ទៅអនាគត សាកលវិទ្យាល័យស្វាយរៀង នឹងអាចបើកមហាវិទ្យាល័យ សាខា ឯកទេស កំរិត ឬប្រភេទ បណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥..**

សាកលវិទ្យាល័យស្វាយរៀង មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និង សម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀត របស់សាកលវិទ្យាល័យ ។

មាត្រា ៦..

សាកលវិទ្យាល័យស្វាយរៀង ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និង សាកលវិទ្យាធិការរង មួយរូប រឺ ច្រើនរូប ជាជំនួយការ ។

មាត្រា ៧..

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រង របស់សាកលវិទ្យាល័យស្វាយរៀង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៨..

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំមន្ត្រីរាជការ ក្របខ័ណ្ឌមុខងារសាធារណៈ ឱ្យបំរើការនៅក្នុងសាកលវិទ្យាល័យស្វាយរៀង តាមការសម្រេចយល់ព្រម ពីទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៩..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
"ដើម្បីជ្រាបជាព័ត៌មាន"
-សាលាខេត្តស្វាយរៀង "ដើម្បីមុខការ"
-ដូចមាត្រា ៩ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ